ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៥ សហវ

ក្រសួងមហាផ្ទៃ

## សារាចរអន្តរក្រសួង

## ស្តីពី

## ការកែសម្រួលឯកសារផ្ទេរធនធានថវិកាពីមូលនិធិឃុំ សង្កាត់ទៅរដ្ឋបាលឃុំ សង្កាត់ និងពីមូលនិធិក្រុង ស្រុក ទៅរដ្ឋបាលក្រុង ស្រុក

យោងអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ និងអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក ដើម្បីបង្កលក្ខណៈងាយស្រួល ព្រមទាំងបានឆាប់រហ័សលើការផ្ទេរធនធានថវិកាសម្រាប់រដ្ឋបាលឃុំ សង្កាត់ និងសម្រាប់រដ្ឋបាលក្រុង ស្រុក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ចេញសារាចរណែនាំដូចខាងក្រោម÷

**១.** កែសម្រួលទម្រង់ឯកសារលើការផ្ទេរធនធានថវិកាសម្រាប់រដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ដោយបញ្ឈប់ការប្រើប្រាស់ "បណ្ណផ្ទេរភារៈចំណាយ" មកប្រើតែ "តារាងផ្ទេរធនធានថវិកា"។

**២. ការផ្ទេរធនធានថវិកាសម្រាប់រដ្ឋបាលឃុំ សង្កាត់**

**២.១. អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ**

អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ក្នុងនាមជាសេនាធិការរបស់ក្រសួងដែលជាម្ចាស់គណនីមូលនិធិឃុំ សង្កាត់ ត្រូវ÷

-រៀបចំសំណើទៅរតនាគារថ្នាក់កណ្តាល ដើម្បីសុំផ្ទេរធនធានថវិកាពីគណនីមូលនិធិឃុំ សង្កាត់ ចំនួន ១ច្បាប់ (ឧបសម្ព័ន្ធទី១) ដោយមានហត្ថលេខារបស់ម្ចាស់គណនីមូលនិធិ ឬ អ្នកទទួលសិទ្ធិ និងគណនេយ្យករ។

-រៀបចំតារាងសរុបចំនួនធនធានថវិការបស់រដ្ឋបាលឃុំ សង្កាត់ តាមរាជធានី ខេត្តចំនួន ១ច្បាប់ ដោយភ្ជាប់ជាមួយសំណើទៅរតនាគារថ្នាក់កណ្តាល។ តារាងសរុបនេះ មានហត្ថលេខាបំពេញរបស់គណនេយ្យករ ឬ អ្នកទទួលសិទ្ធិ និងត្រារបស់អង្គភាពស្នើសុំផ្ទេរធនធានថវិកា (ឧបសម្ព័ន្ធទី២)។

-រៀបចំតារាងរាយលម្អិតឈ្មោះ និងចំនួនទឹកប្រាក់ធនធានថវិការបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ ចំនួន ២ច្បាប់។ តារាងនេះ ត្រូវមានហត្ថលេខាបំពេញរបស់គណនេយ្យករ ឬ អ្នកទទួលសិទ្ធិ និងត្រារបស់អង្គភាពស្នើសុំផ្ទេរធនធានថវិកា ព្រមទាំងមានទំព័រដាច់ដោយឡែកសម្រាប់រាជធានី ខេត្តនីមួយៗ (ឧបសម្ព័ន្ធទី៣)។

**២.២. រតនាគារថ្នាក់កណ្តាល**

យោងតាមឯកសារដូចបានកំណត់នៅចំណុចទី ២.១ ខាងលើ គណនេយ្យកររបស់រតនាគារថ្នាក់កណ្តាលត្រូវ÷

-រៀបចំលិខិតជូនដំណឹងឥណពន្ធ (ទឹកប្រាក់សរុបតាមរាជធានី ខេត្ត) និងសលាកបត្រចុះលេខនា ដើម្បីផ្ទេរថវិកាពីគណនីមូលនិធិឃុំ សង្កាត់ រួចកត់ត្រា÷

ឥណពន្ធ គណនី មូលនិធិ ឃុំ សង្កាត់ (លេខ ៤៤០៩)

ឥណទាន គណនី ទំនាក់ទំនងផ្ទេរប្រតិបត្តិការ (លេខ ៤៣០២)។


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

លិខិតជូនដំណឹងឥណពន្ធត្រូវធ្វើជា ២ច្បាប់ ហើយប្រគល់ជូនម្ចាស់គណនីមូលនិធិឃុំ សង្កាត់ ចំនួន ១ច្បាប់។

-រៀបចំប្រកាសឥណទាន ផ្ទេរធនធានថវិកាពីគណនីមូលនិធិឃុំ សង្កាត់ ចំនួន ២ច្បាប់ ហើយបញ្ជូនទៅរតនាគាររាជធានី ខេត្តពាក់ព័ន្ធ ចំនួន ១ច្បាប់ ដោយភ្ជាប់ជាមួយតារាងរាយលម្អិតឈ្មោះ និងចំនួនធនធានថវិការបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ។

**២.៣.រតនាគាររាជធានី ខេត្ត**

**ក.គណនេយ្យថវិកាថ្នាក់ជាតិ**

យោងប្រកាសឥណទានរបស់រតនាគារថ្នាក់កណ្តាល ស្តីពីការផ្ទេរធនធានថវិកា តារាងរាយលម្អិតឈ្មោះ និងចំនួនធនធានថវិការបស់រដ្ឋបាល ឃុំ សង្កាត់ គណនេយ្យករថវិកាថ្នាក់ជាតិនៃរតនាគាររាជធានី ខេត្ត ត្រូវ÷

-រៀបចំលិខិតជូនដំណឹងឥណទាន ស្តីពីការទទួលធនធានថវិការបស់រដ្ឋបាលឃុំ សង្កាត់ (ទឹកប្រាក់សរុប) និងសលាកបត្រចុះលេខនា រួចកត់ត្រា÷

ឥណពន្ធ គណនី ទំនាក់ទំនងផ្ទេរប្រតិបត្តិការ (លេខ ៤៣០២)

ឥណទាន គណនី ចំណូលផ្សេងៗនិងបង្វែររង់ចាំដោះស្រាយ (លេខ ៤៧០៦) និង

ឥណពន្ធ គណនី ចំណូលផ្សេងៗនិងបង្វែររង់ចាំដោះស្រាយ (លេខ ៤៧០៦)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់ឃុំ សង្កាត់ (លេខ ៤៤០៤)។ ឬ

ឥណពន្ធ គណនី ទំនាក់ទំនងផ្ទេរប្រតិបត្តិការ (លេខ ៤៣០២)

ឥណទាន គណនីប្រាក់បញ្ញើថវិការបស់ឃុំ សង្កាត់ (លេខ ៤៤០៤)។

-គណនេយ្យករថវិកាថ្នាក់ជាតិនៃរតនាគាររាជធានី ខេត្ត ត្រូវប្រគល់លិខិតជូនដំណឹងឥណទាន និងឯកសារពាក់ព័ន្ធ ទៅគណនេយ្យករឃុំ សង្កាត់ ចំនួន ១ច្បាប់។

**ខ.គណនេយ្យឃុំ សង្កាត់**

យោងលិខិតជូនដំណឹងឥណទាន ស្តីពីការផ្ទេរធនធានថវិការបស់ឃុំ សង្កាត់នីមួយៗ តារាងរាយលម្អិតឈ្មោះ និងចំនួនធនធានថវិការបស់រដ្ឋបាលឃុំ សង្កាត់ គណនេយ្យករឃុំ សង្កាត់ ត្រូវ÷

-រៀបចំលិខិតជូនដំណឹងឥណទានស្តីពីការទទួលធនធានថវិការបស់រដ្ឋបាលឃុំ សង្កាត់ (ទឹកប្រាក់ធនធានសម្រាប់ឃុំ សង្កាត់នីមួយៗ) និងសលាកបត្រចុះលេខនា រួចកត់ត្រា÷

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់ឃុំ សង្កាត់ នៅរតនាគារ (លេខ ១២០៤)

ឥណទាន អនុគណនី ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន (លេខ ៧៥០១១)

ឥណទាន អនុគណនី ឧបត្ថម្ភធនពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគ (លេខ ៧៥១១១)

ឥណទាន អនុគណនី ការចូលរួមធនធានពីសមាសភាពអភិវឌ្ឍន៍មូលដ្ឋាន (លេខ ៧៥០៣១)។

**៣.ការផ្ទេរធនធានថវិកាសម្រាប់រដ្ឋបាលក្រុង ស្រុក**

**៣.១.អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនាមជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាម្ចាស់គណនីមូលនិធិក្រុង ស្រុក ត្រូវ÷

-រៀបចំសំណើទៅរតនាគារថ្នាក់កណ្តាល ដើម្បីសុំផ្ទេរធនធានថវិកាពីគណនីមូលនិធិក្រុង ស្រុក ចំនួន ១ច្បាប់ (ឧបសម្ព័ន្ធទី៤)។

-រៀបចំតារាងសរុបធនធានថវិការបស់រដ្ឋបាលក្រុង ស្រុក ទៅតាមខេត្តចំនួន ១ច្បាប់ ប្រគល់ជូនរតនាគារថ្នាក់កណ្តាល។ តារាងសរុបនេះមានហត្ថលេខាបំព្រួញរបស់គណនេយ្យករ ឬ អ្នកទទួលសិទ្ធិ និងត្រារបស់អង្គភាពស្នើសុំផ្ទេរធនធានថវិកា (ឧបសម្ព័ន្ធទី៥)។

-រៀបចំតារាងរាយលម្អិតឈ្មោះ និងចំនួនធនធានថវិការបស់រដ្ឋបាលក្រុង ស្រុកនីមួយៗ ចំនួន ២ច្បាប់។ តារាងនេះត្រូវមានហត្ថលេខាបំព្រួញរបស់គណនេយ្យករ ឬ អ្នកផ្ទេរសិទ្ធិ និងត្រារបស់អង្គភាពស្នើសុំផ្ទេរធនធានថវិកា ព្រមទាំងមានទំព័រដាច់ដោយឡែកសម្រាប់ខេត្តនីមួយៗ (ឧបសម្ព័ន្ធទី៦)។

**៣.២.រតនាគារថ្នាក់កណ្តាល**

យោងឯកសារទាំងឡាយ (ចំណុចទី ៣.១ ខាងលើ) គណនេយ្យកររបស់រតនាគារថ្នាក់កណ្តាលត្រូវ÷

-រៀបចំលិខិតជូនដំណឹងឥណពន្ធ (ទឹកប្រាក់លម្អិតតាមខេត្ត) ផ្ទេរថវិកាពីគណនីមូលនិធិក្រុង ស្រុក ដូចតទៅ÷

ឥណពន្ធ គណនី មូលនិធិក្រុង ស្រុក (លេខ ៤៤០៨)

ឥណទាន គណនី ទំនាក់ទំនងផ្ទេរប្រតិបត្តិការ (លេខ ៤៣០២)។

លិខិតជូនដំណឹងឥណពន្ធ ត្រូវធ្វើជា ២ច្បាប់ ហើយប្រគល់ជូនម្ចាស់គណនីមូលនិធិក្រុង ស្រុក ចំនួន ១ច្បាប់។

-រៀបចំប្រកាសឥណទាន ផ្ទេរធនធានថវិកាពីគណនីមូលនិធិក្រុង ស្រុក ចំនួន ២ច្បាប់ រួចបញ្ជូនទៅរតនាគារខេត្តពាក់ព័ន្ធចំនួន ១ច្បាប់ ដោយភ្ជាប់ជាមួយតារាងរាយលម្អិតឈ្មោះ និងចំនួនធនធានថវិការបស់រដ្ឋបាលក្រុង ស្រុកនីមួយៗ។

**៣.៣.រតនាគារខេត្ត**

**ក.គណនេយ្យថវិកាថ្នាក់ជាតិ**

យោងប្រកាសឥណទានរបស់រតនាគារថ្នាក់កណ្តាល ស្តីពីការផ្ទេរធនធានថវិកា និងតារាងរាយលម្អិតឈ្មោះ និងចំនួនធនធានថវិការបស់រដ្ឋបាលក្រុង ស្រុក គណនេយ្យករថវិកាថ្នាក់ជាតិនៃរតនាគារខេត្ត ត្រូវ÷

-រៀបចំលិខិតជូនដំណឹងឥណទាន ស្តីពីការទទួលធនធានថវិការបស់រដ្ឋបាលក្រុង ស្រុក (ទឹកប្រាក់សរុប) និងសលាកបត្រចុះលេខនា ដូចតទៅ÷

ឥណពន្ធ គណនី ទំនាក់ទំនងផ្ទេរប្រតិបត្តិការ (លេខ ៤៣០២)

ឥណទាន គណនី ចំណូលផ្សេងៗនិងបង្វែររង់ចាំដោះស្រាយ (លេខ ៤៧០៦) និង

ឥណពន្ធ គណនី ចំណូលផ្សេងៗនិងបង្វែររង់ចាំដោះស្រាយ (លេខ ៤៧០៦)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)។ ឬ

ឥណពន្ធ គណនី ទំនាក់ទំនងផ្ទេរប្រតិបត្តិការ (លេខ ៤៣០២)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)។

-គណនេយ្យករថវិកាថ្នាក់ជាតិនៃរតនាគារខេត្ត ត្រូវប្រគល់លិខិតជូនដំណឹងឥណទាន និងឯកសារពាក់ព័ន្ធទៅគណនេយ្យករក្រុង ស្រុក ចំនួន ១ច្បាប់។

**ខ.គណនេយ្យក្រុង ស្រុក**

យោងលិខិតជូនដំណឹងឥណទានរបស់គណនេយ្យករថវិកាថ្នាក់ជាតិ ស្តីពីការផ្ទេរធនធានថវិការបស់រដ្ឋបាលក្រុង ស្រុកនីមួយៗ និងតារាងរាយលម្អិតឈ្មោះនិងចំនួនធនធានថវិការបស់ក្រុង ស្រុក គណនេយ្យករក្រុង ស្រុក ត្រូវ÷

-រៀបចំលិខិតជូនដំណឹងឥណទាន ស្តីពីការទទួលធនធានថវិការបស់រដ្ឋបាលក្រុង ស្រុក (ទឹកប្រាក់ធនធានសម្រាប់ក្រុង ស្រុកនីមួយៗ) និងសលាកបត្រចុះលេខនា ដូចតទៅ÷

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)

ឥណទាន អនុគណនី ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន (លេខ ៧៥០១១)។

ទទួលបានសារាចរអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ២០២២

| | |
|---|---|
| ឧបនាយករដ្ឋមន្ត្រី | ឧបនាយករដ្ឋមន្ត្រី |
| រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| សម្តេចក្រឡាហោម ស ខេង | អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន |

**កន្លែងទទួល៖**

- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សាលារាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- គ្រប់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី ១**

ថ្ងៃ............ ខែ....... ឆ្នាំ....... ព.ស........

រាជធានីភ្នំពេញ ថ្ងៃ.........ខែ.......... ឆ្នាំ.......

**ជម្រាបជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**កម្មវត្ថុ ÷** សំណើសុំផ្ទេរធនធានថវិកា ពីមូលនិធិឃុំ សង្កាត់ លើកទី... មានចំនួនទឹកប្រាក់ ............. រៀល (...ទឹកប្រាក់ជាអក្សររៀលកត់) ទៅគណនីប្រាក់បញ្ញើរបស់រដ្ឋបាលឃុំសង្កាត់នៅរតនាគាររាជធានី ខេត្ត ទូទាំងប្រទេស។

**យោង ÷** - អនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីចំណូលមូលនិធិឃុំ សង្កាត់

- អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ ស្តីពីការផ្ទេរធនធានពីថវិកាជាតិជូនមូលនិធិឃុំ សង្កាត់
- លិខិតលេខ ..សហវ.អហក ចុះថ្ងៃទី... ខែ... ឆ្នាំ២០... ស្តីពីការផ្ទេរវិភាជន៍ធនធានមូលនិធិឃុំ សង្កាត់ទូទាំងប្រទេសសម្រាប់ឆ្នាំ២០...
- អាណត្តិបើកប្រាក់លេខ.... ចុះថ្ងៃទី...ខែមករា ឆ្នាំ២០... របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការផ្តល់ឧបត្ថម្ភធនដល់មូលនិធិឃុំ សង្កាត់ សម្រាប់ត្រីមាសទី... ឆ្នាំ២០...។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** មេត្តាជ្រាបថា÷ ធនធានមូលនិធិឃុំ សង្កាត់ សម្រាប់ឆ្នាំ២០... ត្រូវបានរាជរដ្ឋាភិបាលផ្តល់ជូនរដ្ឋបាលឃុំ សង្កាត់ នៅទូទាំងប្រទេសមានចំនួនសរុប....រៀល។ យោងតាមអាណត្តិបើកប្រាក់លេខ.....ផ្តល់ឧបត្ថម្ភធនសម្រាប់ត្រីមាសទី... ឆ្នាំ២០... ដល់រដ្ឋបាលឃុំ សង្កាត់ ក្រសួងមហាផ្ទៃបានសម្រេចធ្វើការផ្ទេរធនធានថវិកាចំនួន .... រៀល ជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ត្រីមាសទី ... នៃចំណាយដំណើរការរដ្ឋបាលចំនួន ២៥% និងចំណាយអភិវឌ្ឍន៍ចំនួន ២៥%។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** មេត្តាផ្ទេរធនធានថវិកាពីមូលនិធិឃុំ សង្កាត់ នូវចំនួនទឹកប្រាក់ខាងលើ ទៅគណនីប្រាក់បញ្ញើរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ នៅរតនាគាររាជធានី ខេត្ត តាមការគួរ។

សូមជូនភ្ជាប់មកជាមួយនូវ÷

- តារាងសរុបផ្ទេរធនធានថវិការបស់រដ្ឋបាលឃុំ សង្កាត់ ត្រីមាសទី... ឆ្នាំ២០... ចំនួន ១ច្បាប់
- តារាងរាយលម្អិតផ្ទេរធនធានថវិការបស់រដ្ឋបាលឃុំ សង្កាត់ ត្រីមាសទី... ឆ្នាំ២០... នៅរដ្ឋបាលរាជធានី ខេត្ត ចំនួន ១ច្បាប់។

សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** ទទួលនូវការគោរពរាប់អាន ពីខ្ញុំ

**អគ្គនាយក** **គណនេយ្យករ**

**<u>ចម្លងជូន÷</u>**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន គ.ជ.អ.ប

"ដើម្បីជ្រាប"

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានរដ្ឋបាល

ឧបសម្ព័ន្ធទី ២

**តារាងសរុបផ្ទេរធនធានថវិការបស់រដ្ឋបាលឃុំ សង្កាត់ ត្រីមាសទី... ឆ្នាំ២០...**

| ល.រ | ឈ្មោះរាជធានី ខេត្ត | ឃុំ សង្កាត់ | ក្រុមប្រឹក្សា | ភូមិ | ធនធានថវិកាត្រីមាស... | | |
|---|---|---|---|---|---|---|---|
| | | | | | រដ្ឋបាល(២៥%) | អភិវឌ្ឍន៍(២៥%) | សរុប |
| ០១ | បន្ទាយមានជ័យ | 67 | 92 | 84 | 522,777,500 | 418,152,500 | 940,930,000 |
| ០២ | បាត់ដំបង | | | | | | |
| ០៣ | កំពង់ចាម | | | | | | |
| ០៤ | កំពង់ឆ្នាំង | | | | | | |
| ០៥ | កំពង់ស្ពឺ | | | | | | |
| ០៦ | កំពង់ធំ | | | | | | |
| ០៧ | កំពត | | | | | | |
| ០៩ | កោះកុង | | | | | | |
| ១០ | ក្រចេះ | | | | | | |
| ១១ | មណ្ឌលគិរី | | | | | | |
| ១២ | ភ្នំពេញ | | | | | | |
| ១៣ | ព្រះវិហារ | | | | | | |
| ១៤ | ព្រៃវែង | | | | | | |
| ១៥ | ពោធិសាត់ | | | | | | |
| ១៦ | រតនគិរី | | | | | | |
| ១៧ | សៀមរាប | | | | | | |
| ១៨ | ព្រះសីហនុ | | | | | | |
| ១៩ | ស្ទឹងត្រែង | | | | | | |
| ២០ | ស្វាយរៀង | | | | | | |
| ២១ | តាកែវ | | | | | | |
| ២២ | ឧត្តរមានជ័យ | | | | | | |
| ២៣ | កែប | | | | | | |
| ២៤ | ប៉ៃលិន | | | | | | |
| ២៥ | ត្បូងឃ្មុំ | | | | | | |
| | សរុប | ..... | ... | ... | 11,242,077,500 | 8,127,877,500 | 19,369,955,000 |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានរដ្ឋបាល

ឧបសម្ព័ន្ធទី ៣

## តារាងរាយលម្អិតផ្ទេរធនធានថវិការបស់រដ្ឋបាលឃុំ សង្កាត់ ត្រីមាសទី... ឆ្នាំ២០... នៅរដ្ឋបាលរាជធានី ខេត្ត

### ០១. បន្ទាយមានជ័យ

| លេខកូដ | ឈ្មោះសង្កាត់ | ក្រុមប្រឹក្សា | ភូមិ | វិភាជន៍ថវិកាត្រីមាសទី... | | |
|---|---|---|---|---|---|---|
| | | | | រដ្ឋបាល(២៥%) | អភិវឌ្ឍន៍(២៥%) | សរុប |
| **0106** | **សិរីសោភ័ណ** | | | | | |
| 010602 | កំពង់ស្វាយ | 11 | 9 | 58,957,500 | 47,175,000 | 106,132,500 |
| 010603 | កោះពងសត្វ | | | | | |
| 010604 | ម្កាក់ | | | | | |
| 010605 | អូរអំបិល | | | | | |
| 010606 | ភ្នៀត | | | | | |
| 010607 | ព្រះពន្លា | | | | | |
| 010608 | ទឹកថ្លា | | | | | |
| | **សរុបរង** | .... | .... | | | |
| **0110** | **ប៉ោយប៉ែត** | | | | | |
| 011001 | និមិត្ត | | | | | |
| 011102 | ប៉ោយប៉ែត | | | | | |
| 011103 | ផ្សារកណ្ដាល | | | | | |
| | **សរុបរង** | .... | .... | | | |
| | ***សរុបរួម*** | .... | .... | 522,777,500 | 418,152,500 | 940,930,000 |

**ឧបសម្ព័ន្ធទី ៤**

ថ្ងៃ............ ខែ....... ឆ្នាំ...... ព.ស.........

រាជធានីភ្នំពេញ ថ្ងៃ.........ខែ.......... ឆ្នាំ.......

**ជម្រាបជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**

**នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**កម្មវត្ថុ** ÷ ការផ្ទេរធនធានមូលនិធិសម្រាប់ចំណាយឧបត្ថម្ភតុល្យភាពថវិកាជូនរដ្ឋបាលក្រុង ស្រុក សម្រាប់ត្រីមាសទី.... ឆ្នាំ...... ចំនួន............រៀល(ជាអក្សរ) ទៅក្នុងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុក ដូចមានក្នុងតារាងភ្ជាប់មកជាមួយនេះ។

**យោង** ÷ លិខិតរបស់រដ្ឋបាលក្រុង ស្រុក ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ។

**ភ្ជាប់ជូន** ÷ -តារាងសរុបផ្ទេរធនធានថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រីមាសទី... ឆ្នាំ២០...

-តារាងរាយលម្អិតផ្ទេរធនធានថវិការបស់រដ្ឋបាលក្រុង ស្រុក នៃខេត្ត..... សម្រាប់ត្រីមាសទី... ឆ្នាំ២០...។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលជ្រាបថា÷ ដើម្បីឧបត្ថម្ភតុល្យភាពថវិកា ជូនរដ្ឋបាលក្រុង ស្រុក ចំនួន....../...នៃខេត្ត..... សម្រាប់ត្រីមាសទី..... ឆ្នាំ....... ក្នុងនាមជាម្ចាស់គណនីមូលនិធិក្រុង ស្រុក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសម្រេចផ្ទេរធនធានចំនួន..............រៀល (ជាអក្សរ) ពីមូលនិធិក្រុង ស្រុក ជូនរដ្ឋបាលក្រុង ស្រុក ទៅតាមចំនួនដូចមានក្នុងតារាងភ្ជាប់មកជាមួយនេះ។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ផ្ទេរធនធានពីមូលនិធិក្រុង ស្រុក តាមចំនួនសរុបដូចដែលបានស្នើខាងលើ ទៅក្នុងគណនីប្រាក់បញ្ញើ របស់រដ្ឋបាលក្រុង ស្រុកតាមការគួរ។

សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលនូវការរាប់អានពីខ្ញុំ

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ** |

**<u>កន្លែងទទួល:</u>**

- ក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលខេត្ត........
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត........
- រតនាគារខេត្ត.........
- រដ្ឋបាលក្រុង ស្រុកសាមី
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ** **ឧបសម្ព័ន្ធទី ៥**

## តារាងសរុបផ្ទេរធនធានថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រីមាសទី... ឆ្នាំ២០...

| ល.រ | ឈ្មោះរាជធានី ខេត្ត | ក្រុង ស្រុក ដែលត្រូវផ្ទេរ | ធនធានថវិកាដែលត្រូវផ្ទេរ | ផ្សេងៗ |
|---|---|---|---|---|
| ០១ | បន្ទាយមានជ័យ | 67 | | - |
| ០២ | បាត់ដំបង | | | |
| ០៣ | កំពង់ចាម | | | |
| ០៤ | កំពង់ឆ្នាំង | | | |
| ០៥ | កំពង់ស្ពឺ | | | |
| ០៦ | កំពង់ធំ | | | |
| ០៧ | កំពត | | | |
| ០៩ | កោះកុង | | | |
| ១០ | ក្រចេះ | | | |
| ១១ | មណ្ឌលគិរី | | | |
| ១២ | ភ្នំពេញ | | | |
| ១៣ | ព្រះវិហារ | | | |
| ១៤ | ព្រៃវែង | | | |
| ១៥ | ពោធិសាត់ | | | |
| ១៦ | រតនគិរី | | | |
| ១៧ | សៀមរាប | | | |
| ១៨ | ព្រះសីហនុ | | | |
| ១៩ | ស្ទឹងត្រែង | | | |
| ២០ | ស្វាយរៀង | | | |
| ២១ | តាកែវ | | | |
| ២២ | ឧត្តរមានជ័យ | | | |
| ២៣ | កែប | | | |
| ២៤ | ប៉ៃលិន | | | |
| ២៥ | ត្បូងឃ្មុំ | | | |
| | សរុប | .... | 11,242,077,500 | 11,242,077,500 |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

ឧបសម្ព័ន្ធទី ៦

**តារាងរាយលម្អិតផ្ទេរធនធានថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ត្រីមាសទី... ឆ្នាំ២០... នៅរាជធានី ខេត្ត**

**០១. បន្ទាយមានជ័យ**

| លេខកូដ | ឈ្មោះក្រុង ស្រុក | ធនធានថវិកាដែលត្រូវផ្ទេរ | ផ្សេងៗ |
|---|---|---|---|
| 0102 | ស្រុកមង្គលបូរី | | |
| 0103 | ស្រុកភ្នំស្រុក | | |
| 0104 | ស្រុកព្រះនេត្រព្រះ | | |
| 0105 | ស្រុកអូរជ្រៅ | | |
| 0106 | ក្រុងសិរីសោភ័ណ | | |
| 0107 | ស្រុកថ្មពួក | | |
| 0108 | ស្រុកស្វាយចេក | | |
| 0109 | ស្រុកម៉ាឡៃ | | |
| 0110 | ក្រុងប៉ោយប៉ែត | | |
| | *សរុប* | 522,777,500 | |